# DE INTERNATIONAL

## WELFARE POLICY

### លក្ខខណ្ឌតម្រូវសុខុមាលភាពសម្រាប់និស្សិតអន្តរជាតិនៅសាលារៀនរដ្ឋក្នុងរដ្ឋញូវសៅវែល (NSW)៖

- **សិស្សនៅសាលាបឋមសិក្សា ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី4** ត្រូវតែរស់នៅជាមួយឪពុកម្ដាយរបស់ពួកគេ។ សិស្សបឋមសិក្សាថ្នាក់ទី5 ឬទី6 អាចរស់នៅជាមួយឪពុកម្ដាយ ឬសាច់ញាតិជិតស្និទ្ធដែលបានអនុម័តដោយក្រសួងកិច្ចការផ្ទៃក្នុង។
- **សិស្សថ្នាក់ទី7 និងទី8** អាចរស់នៅជាមួយឪពុកម្ដាយ ឬសាច់ញាតិជិតស្និទ្ធដែលបានអនុម័តដោយក្រសួងកិច្ចការផ្ទៃក្នុង។
- **សិស្សថ្នាក់ទី9 ដល់ថ្នាក់ទី12** អាចរស់នៅជាមួយឪពុកម្ដាយ សាច់ញាតិដែលបានអនុម័ត ឬរស់នៅក្នុងលំនៅដ្ឋានគ្រួសារក្នុងតំបន់ (homestay)។

### ក្រសួងកិច្ចការផ្ទៃក្នុងតម្រូវឱ្យអ្នកកាន់ទិដ្ឋាការសិស្សអាយុក្រោម18ឆ្នាំ៖

1. **រស់នៅជាមួយឪពុកម្ដាយ ឬសាច់ញាតិដែលសមរម្យ (ដូចដែលបានកំណត់ដោយក្រសួងកិច្ចការផ្ទៃក្នុង។** ឪពុកម្ដាយអាចអមទៅជាមួយកូនរបស់ពួកគេបាននៅក្រោមទិដ្ឋាការអាណាព្យាបាល។ ឪពុកម្ដាយត្រូវតែបំពេញសេចក្ដីប្រកាសរបស់ឪពុកម្ដាយសម្រាប់អ្នកដាក់ពាក្យសុំទិដ្ឋាការអាណាព្យាបាល។ ជាជម្រើសផ្សេង ឪពុកម្ដាយអាចជ្រើសតាំងសាច់ញាតិសមស្របម្នាក់ដែលមានអាយុលើសពី25ឆ្នាំ ហើយមានអត្តចរិតល្អ។ សាច់ញាតិត្រូវផ្ដល់លិខិតបញ្ជាក់ថាលទោស (police check) និងភស្តុតាងនៃទំនាក់ទំនងគ្រួសារជាផ្នែកនៃការដាក់ពាក្យសុំទិដ្ឋាការសិស្ស។ ឈ្មោះ អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងរបស់សាច់ញាតិត្រូវបានផ្ដល់ជូនទៅ DE International នៅក្នុងទម្រង់ពាក្យសុំ ហើយឪពុកម្ដាយ និងសាច់ញាតិត្រូវបំពេញទម្រង់បែបបទជ្រើសតាំងសាច់ញាតិជិតស្និទ្ធ។ សិស្សត្រូវតែរស់នៅជាមួយសាច់ញាតិនេះ។

ឬ

2. **រស់នៅក្រោមការរៀបចំដែលបានអនុម័តដោយអ្នកផ្ដល់សេវាកម្មអប់រំរបស់ពួកគេ។** ឪពុកម្ដាយត្រូវតែស្នើសុំក្រសួងអប់រំរដ្ឋ NSW ដើម្បីរៀបចំលំនៅដ្ឋានគ្រួសារក្នុងតំបន់។

បន្ទាប់មក DE International នឹងចេញទម្រង់បែបបទ ការបញ្ជាក់ពីទីស្នាក់អាស្រ័យ និងសុខុមាលភាពសមរម្យ CAAW សម្រាប់ទិដ្ឋាការរបស់សិស្ស។ ប្រសិនបើទម្រង់បែបបទ CAAW ត្រូវបានចេញឱ្យ សិស្សត្រូវតែរស់នៅក្នុងលំនៅដ្ឋានគ្រួសារក្នុងតំបន់ ដែលបានអនុម័តដោយក្រសួងអប់រំរដ្ឋ NSW ។

គ្រួសារម្ចាស់លំនៅដ្ឋានក្នុងតំបន់ត្រូវតែ៖

- ចុះឈ្មោះជាមួយអ្នកផ្ដល់សេវាកម្មលំនៅដ្ឋានគ្រួសារក្នុងតំបន់ (Homestay Provider) ដោយមានកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំរដ្ឋ NSW
- ត្រូវតែមាន Working with Children Check ( សំបុត្របញ្ជាក់ថាអាចធ្វើការជាមួយកុមារបាន ) (WWCC) សម្រាប់មនុស្សពេញវ័យទាំងអស់ដែលរស់នៅក្នុងផ្ទះនោះ
- បំពេញតាមលក្ខខណ្ឌ ដូចដែលបានគូសបញ្ជាក់នៅក្នុង **សន្លឹកព័ត៌មានអំពីលំនៅដ្ឋានគ្រួសារក្នុងតំបន់សម្រាប់ឪពុកម្ដាយ**
- យល់ព្រមទទួលយកទំនួលខុសត្រូវ ក្នុងភាពជាអ្នកថែទាំសម្រាប់សិស្សដែលមានអាយុក្រោម18ឆ្នាំ ដូចដែលបានគូសបញ្ជាក់នៅលើទម្រង់បែបបទអ្នកថែទាំលំនៅដ្ឋានគ្រួសារក្នុងតំបន់។

ទីស្នាក់អាស្រ័យលំនៅដ្ឋានគ្រួសារក្នុងតំបន់ ត្រូវបានរៀបចំសម្រាប់តែសិស្សប៉ុណ្ណោះ។ ឪពុកម្ដាយ ឬសាច់ញាតិដែលមកលេង ត្រូវតែស្វែងរកការរៀបចំទីស្នាក់អាស្រ័យឯករាជ្យមួយផ្សេងទៀត។

ឪពុកម្ដាយសិស្សថ្នាក់ទី9 ដល់ថ្នាក់ទី12 អាចស្នើសុំការអនុម័តសម្រាប់កូនរបស់ពួកគេឱ្យរស់នៅជាមួយសាច់ញាតិឆ្ងាយ ឬមិត្តភក្ដិគ្រួសារ ប្រសិនបើពួកគេបានបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសារនោះរួចហើយ។ ការរៀបចំទាំងនេះត្រូវបានគេហៅថា **លំនៅដ្ឋានគ្រួសារក្នុងតំបន់ដែលបានជ្រើសតាំងដោយឪពុកម្ដាយ (Parent Nominated Homestays)** ហើយត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់លំនៅដ្ឋានគ្រួសារក្នុងតំបន់ដូចគ្នា។ ជាផលប្រយោជន៍ដល់ការអភិវឌ្ឍន៍ភាសារបស់សិស្ស យើងណែនាំឱ្យពួកគេរស់នៅក្នុងផ្ទះដែលនិយាយភាសាអង់គ្លេស។

ដើម្បីទទួលបានការអនុម័ត គ្រួសារដែលបានជ្រើសតាំងត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់ នៃលំនៅដ្ឋានគ្រួសារក្នុងតំបន់ដែលបានចុះបញ្ជីដូចដែលបានចែងខាងលើ។ នីតិវិធីខាងក្រោមត្រូវបានទាមទារឱ្យអនុវត្ត ហើយអាចចំណាយពេលពីបួន ទៅប្រាំមួយសប្ដាហ៍ដើម្បីបញ្ចប់៖

- ឪពុកម្ដាយជ្រើសតាំងគ្រួសារនៅលើ**ទម្រង់ពាក្យសុំ**ឬបំពេញទម្រង់បែបបទ **លំនៅដ្ឋានគ្រួសារក្នុងតំបន់ដែលបានជ្រើសតាំងដោយឪពុកម្ដាយ (Parent Nominated Homestay)**ដែលអាចរកបាននៅ DE International។ ត្រូវបំពេញ ហើយបញ្ជូនទម្រង់បែបបទនេះទៅ DE International។ ឪពុកម្ដាយត្រូវតែជូនដំណឹងដល់គ្រួសារអំពីលក្ខខណ្ឌតម្រូវនានា។
- គ្រួសារដែលបានជ្រើសតាំង ត្រូវបានបញ្ជូនទៅអ្នកផ្ដល់សេវាកម្មលំនៅដ្ឋានគ្រួសារក្នុងតំបន់សម្រាប់ការចុះឈ្មោះ។ អាចមានការចំណាយប្រាក់សម្រាប់ការចុះឈ្មោះជាមួយអ្នកផ្ដល់សេវាកម្មលំនៅដ្ឋានគ្រួសារក្នុងតំបន់។
- មនុស្សពេញវ័យទាំងអស់ (អាយុលើសពី18ឆ្នាំ) ដែលរស់នៅក្នុងផ្ទះត្រូវតែមាន Working with Children Check ( សំបុត្របញ្ជាក់ថាអាចធ្វើការជាមួយនឹងកុមារបាន ) (WWCC) ហើយផ្ទះនោះនឹងត្រូវបានត្រួតពិនិត្យ ហើយត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់។
- អ្នកផ្ដល់សេវាកម្មលំនៅដ្ឋានគ្រួសារក្នុងតំបន់ នឹងផ្ញើរបាយការណ៍មួយស្ដីពីផ្ទះជាមួយនឹងច្បាប់ចម្លងនៃ WWCC ទៅ DE International ។
- **ប្រសិនបើបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់ លំនៅដ្ឋានគ្រួសារក្នុងតំបន់នឹងត្រូវបានអនុម័ត។**

### ការមកដល់ប្រទេសអូស្ត្រាលី

- សិស្សដែលឪពុកម្ដាយរបស់ខ្លួនកំពុងដាក់ពាក្យសុំទិដ្ឋាការអាណាព្យាបាល រួមទាំងសិស្សដែលកំពុងចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី4 ត្រូវតែអមដំណើរដោយឪពុកម្ដាយរបស់ពួកគេ។
- សិស្សដែលសាច់ញាតិជិតស្និទ្ធរបស់ខ្លួនត្រូវបានអនុម័តដោយក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរទៅប្រទេសអូស្ត្រាលីដោយគ្មានអ្នកអមដំណើរ ប៉ុន្តែត្រូវតែមានសាច់ញាតិដែលបានអនុម័តរង់ចាំទទួលនៅឯព្រលានយន្តហោះ។
- សិស្សដែលមានអ្នកថែទាំដែលជ្រើសតាំងដោយឪពុកម្ដាយត្រូវបានអនុម័តដោយក្រសួងអប់រំរដ្ឋ NSW ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរទៅប្រទេសអូស្ត្រាលីដោយគ្មានអ្នកអមដំណើរ ប៉ុន្តែត្រូវតែមានអ្នកថែទាំដែលបានអនុម័តរង់ចាំទទួលនៅឯព្រលានយន្តហោះ។
- សិស្សដែលឪពុកម្ដាយរបស់ខ្លួនបានស្នើសុំដាក់ឱ្យរស់នៅជាមួយលំនៅដ្ឋានគ្រួសារក្នុងតំបន ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរទៅប្រទេសអូស្ត្រាលីដោយគ្មានអ្នកអមដំណើរ ប៉ុន្តែត្រូវតែបានរង់ចាំទទួលដោយដោយសេវាកម្ម 'ទៅទទួលនៅព្រលានយន្តហោះ' របស់អ្នកផ្ដល់សេវាកម្មលំនៅដ្ឋានគ្រួសារក្នុងតំបនះដែលបានអនុម័ត។